**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៦៩៧.....សហវ.ប្រក

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការកែសម្រួលអត្រាពន្ធគយ លើមុខទំនិញនាំចូលមួយចំនួន ពាក់ព័ន្ធនឹងឧបករណ៍បរិក្ខារថាមពលកកើតឡើងវិញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករាឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ៤៦៥ សហវ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៧
- បានឃើញ ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩ លើលិខិតលេខ ៤២៨៨សហវចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់ ដើម្បីជម្រុញការអភិវឌ្ឍអគ្គិសនីការូបនីយកម្មជនបទ

**សម្រេច**

**ប្រការ ១.-**

ត្រូវបានកែសម្រួលអត្រាពន្ធគយពីអត្រា សាមសិបប្រាំភាគរយ ( ៣៥% ) មកអត្រា ប្រាំពីរភាគរយ ( ៧% ) ចំពោះមុខទំនិញនាំចូលមួយចំនួននៃតារាងពន្ធគយកម្ពុជាជាធរមានដែលមានលេខសម្គាល់ទីតាំងរង ៨៥០៤.៤០.១១, ៨៥០៤.៤០.១៩, ៨៥០៤.៤០.២០, ៨៥០៤.៤០.៣០, ៨៥០៤.៤០.៤០, ៨៥០៤.៤០.៩០, ៨៥០៧.២០.១០, ៨៥០៧.២០.៩០, ៨៥៤១.៤០.១០, ៨៥៤១.៤០.២០, និងទីតាំងរង ៨៥៤១.៤០.៩០ ។

**ប្រការ ២.-**

ត្រូវបានកែសម្រួលអត្រាពន្ធគយពីអត្រា ដប់ប្រាំភាគរយ ( ១៥% )មកអត្រា សូន្យភាគរយ ( ០% )ចំពោះមុខទំនិញនាំចូលមួយចំនួននៃតារាងពន្ធគយកម្ពុជាជាធរមានដែលមានលេខសម្គាល់ទីតាំងរង ៨៤០៤.១០.១០, ៨៤០៤.១០.២០, ៨៤០៤.២០.០០, ៨៤០៤.៩០.១១, ៨៤០៤.៩០.១៩, ៨៤០៤.៩០.២១, ៨៤០៤.៩០.២៩, ៨៤០៤.៩០.៩០, ៨៤១០.១១.០០, ៨៤១០.១២.០០, ៨៤១០.១៣.០០, ៨៤១០.៩០.០០, ៨៤១៣.១៩.១០, ៨៤១៣.៨១.១០, ៨៤១៦.៣០.០០, ៨៤១៦.៩០.០០, ៨៤១៩.១១.១០, ៨៤១៩.១១.៩០, ៨៤១៩.១៩.១០, ៨៤១៩.១៩.៩០, ៨៥០២.៣១.១០, ៨៥០២.៣១.៩០, ៨៥០២.៣៩.១០, ៨៥០២.៣៩.២០, ៨៥០២.៣៩.៣១, ៨៥០២.៣៩.៣៩, ៨៥០២.៤០.០០, និងទីតាំងរង ៩៤០៥.៤០.៥០ ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**__ចម្លងជូន៖__**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ